00611384

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

លេខ/No: D427/1/3

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-**អវកត/កសចស(អបជ៧៥)** |
| **ចំពោះមុខ៖** | **ចៅក្រម ប្រាក់ គឹមសាន ប្រធាន** |
| | **ចៅក្រម Rowan DOWNING** |
| | **ចៅក្រម ន៍យ ថុល** |
| | **ចៅក្រម Catherine MARCHI-UHEL** |
| | **ចៅក្រម ហួត វុទ្ធី** |
| **កាលបរិច្ឆេទ៖** | **ថ្ងៃទី១ ខែតុលា ឆ្នាំ២០១០** |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 10 / 2010
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**សាធារណៈ:**

**សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រ សម្រាប់ ដាក់បណ្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ**

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

**<u>ជនត្រូវចោទ</u>**

អៀង សារី

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

លោក គឹម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោកស្រី Fabienne TRUSSES-NAPROUS

**<u>សហមេធាវីការពារក្តីជនត្រូវចោទ</u>**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

លោកស្រី Elizabeth-Joelle RABESANRATANA

លោកស្រី Annie DELAHAIE

លោក នី ចាន់ឌី

លោក ឡោ ជុនធី

លោកស្រី Silke STUDZINSKY

លោក គង់ ពិសី

លោក ហុង គីមសួន

លោក យុង ផានិត

លោកស្រី ស៊ីន សុវ៉ន

លោក Mahdev MOHAN

លោកស្រី Lyma NGUYEN

លោកស្រី Marie GUIRAUD

លោក Partirck BAUDOIN

លោក Olivier BAHOUGNE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រ សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការនានា ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ" ដែលដាក់ដោយសហមេធាវីការពារក្តីរបស់ជនត្រូវចោទ កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ ("សំណើសុំ")[១]។

១. សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០[២]។ ភាគីទាំងឡាយត្រូវបានជូនដំណឹងអំពីដីកាដំណោះស្រាយ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០។

២. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានដាក់ការជូនដំណឹងអំពីការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[៣]។ ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០។

៣. សហមេធាវីការពារក្តីបានដាក់សំណើសុំ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ ដដែលនេះដែរ។ សំណើសុំនេះត្រូវបានជូនដំណឹង នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០។

៤. នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ "សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញាទៅលើសំណើរបស់ អៀង សារី សុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ"[៤]។

---

[១] សំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D427/1/1 ("សំណើសុំ")។

[២] ដីកាដំណោះស្រាយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។ ឯកសារ D427។

[៣] សៀវភៅចុះបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីឱ្យ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427/1។

[៤] សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញា ទៅលើសំណើរបស់ អៀង សារី សុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427/1/2 ("សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញា")។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00611387



៥. នៅក្នុងសំណើសុំនេះ សហមេធាវីការពារក្តីជនត្រូវចោទស្នើសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍នេះ សរុបទាំងអស់ចំនួនមួយរយប៉ែតសិប (១៨០) ទំព័រ។

៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីបានលើកឡើងនៅក្នុងសំណើសុំរបស់ខ្លួនថា ខ្លួនមានបំណងដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ "ទៅនឹងផ្នែកខ្លះនៃដីកាដំណោះស្រាយដែលបញ្ជាក់អះអាងពីយុត្តាធិការរបស់ អ.វ.ក.ត" ហើយបើទោះបីជាវិធានផ្ទៃក្នុងមិនបានហាមឃាត់ឱ្យពួកគាត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នា ដែលបណ្តឹងឧទ្ធរណ៍មួយមានកម្រិតត្រឹមតែចំនួន ៣០ ទំព័រ ទាក់ទងទៅនឹងបញ្ហាយុត្តាធិការក៏ដោយ ក៏វាជាបញ្ហាផលប្រយោជន៍នៃធនធានរបស់តុលាការ ដើម្បីដោះស្រាយបញ្ហាទាំងអស់នៅក្នុងបណ្តឹងតែមួយ។ សហមេធាវីការពារក្តីលើកឡើងថែមទៀតថា មានកាលៈទេសៈលើកលែងពិសេសដែលតម្រូវឱ្យមានការបន្ថែមចំនួនទំព័រ ដែលអនុវត្តបានចំពោះបណ្តឹងឧទ្ធរណ៍នេះ ដោយមូលហេតុថា បញ្ហាយុត្តាធិការនានាដែលនឹងត្រូវដោះស្រាយ មានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំង និងអាចមានចំនួនរហូតដល់ ៣០ ទំព័រ សម្រាប់បញ្ហាយុត្តាធិការនីមួយៗ។ សហមេធាវីការពារក្តីលើកឡើងថា ខ្លួនមិនអាចមានលទ្ធភាពផ្តល់ឧត្តមប្រយោជន៍ឱ្យកូនក្តីរបស់ខ្លួនបានទេ ប្រសិនបើសំណើសុំបន្ថែមចំនួនទំព័ររបស់ខ្លួន មិនត្រូវបានអនុញ្ញាតតាមការស្នើសុំទេនោះ។

៧. សហព្រះរាជអាជ្ញាបានជំទាស់តវ៉ាទៅនឹងការអះអាងរបស់សហមេធាវីការពារក្តី ដែលថាសារណាដាច់ដោយឡែកៗពីគ្នាដែលមានចំនួន ៣០ ទំព័រ អាចត្រូវបានដាក់ជូន ដើម្បីជំទាស់ទៅនឹងយុត្តាធិការដាច់ដោយឡែកៗពីគ្នា ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ និងបានទាមទារឱ្យភាគីប្តឹងឧទ្ធរណ៍លើកឡើងនូវការជំទាស់តវ៉ាទាំងអស់ នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍សង្ខេបតែមួយ[៥]។

៨. ដោយសារថា ដីកាដំណោះស្រាយបានលើកឡើងពីបញ្ហាយុត្តាធិការជាច្រើន នោះសហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍នេះទេ។ ប៉ុន្តែយោងតាមបទប្បញ្ញត្តិនានា នៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក

---

[៥] សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

និងយោងតាមការអនុវត្តជាក់ស្តែងដែលត្រូវបានអនុវត្ត នៅតុលាការអន្តរជាតិដទៃទៀត សហព្រះរាជអាជ្ញាយល់ឃើញថា សំណើសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍នេះ ដែលមានចំនួនសរុប ១៨០ ទំព័រ គឺជាចំនួនច្រើនលើសលុប ដោយសារហេតុផលដូចខាងក្រោមនេះ[៦]: (១) វិធានផ្ទៃក្នុងពុំមានបំណងឲ្យមេធាវីការពារក្តី ប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាដំណោះស្រាយទាំងមូលនោះទេ ហើយអង្គបុរេជំនុំជម្រះក៏មិនបានអះអាងថា ក្នុងកាលៈទេសៈបែបណាដែលបណ្តឹងឧទ្ធរណ៍បែបនេះអាចនឹងទទួលយកបាននោះដែរ[៧] (២) ឥឡូវនេះ ដើមបណ្តឹងឧទ្ធរណ៍ត្រូវបានរារាំងមិនឲ្យជំទាស់តវ៉ាទៅលើបញ្ហាយុត្តាធិការនានា ដែលបានបញ្ជាក់អះអាងដោយសហចៅក្រមស៊ើបអង្កេត នៅដំណាក់កាលដំបូង ហើយដែលនៅពេលនោះ ដើមបណ្តឹងឧទ្ធរណ៍បានសម្រេចមិនប្តឹងឧទ្ធរណ៍ទេ[៨] (៣) អង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជំនុំជម្រះបានសម្រេចបញ្ហាយុត្តាធិការមួយចំនួន ដែលបានលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍[៩] នៅក្នុងឱកាសផ្សេងៗគ្នាជាច្រើនរួចមកហើយ។ សហព្រះរាជអាជ្ញាស្នើសុំឲ្យកម្រិតការបន្ថែមចំនួនទំព័រនេះជាអតិបរមាត្រឹម ៦០ ទំព័រតែប៉ុណ្ណោះ[១០]។

៩. អនុលោមតាមមាត្រា ៥(៤) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (វិសោធនកម្មលើកទី ៤) តាមសំណើសុំរបស់ភាគីចូលរួម អង្គបុរេជំនុំជម្រះអាចបន្ថែមចំនួនទំព័រឯកសារនៅក្នុងកាលៈទេសៈពិសេស។

១០. អង្គបុរេជំនុំជម្រះយល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថា ការអះអាងរបស់សហមេធាវីការពារក្តីថា សារណាសង្ខេបដែលមានចំនួន ៣០ ទំព័រ អាចត្រូវបានដាក់ជូនប្រឆាំងទៅនឹងបញ្ហាយុត្តាធិការដាច់ដោយឡែកៗពីគ្នា ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយតែមួយ

---

[៦] សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២, ៣ និង ៩។

[៧] សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤។

[៨] សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤ ដល់ ៧។

[៩] សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨។

[១០] សេចក្តីអង្កេតរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩។

គឺមិនត្រឹមត្រូវនោះទេ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហាចំនួនប្រាំពីរ ដែលបានលើកឡើងថាជាបញ្ហាយុត្តាធិការដែលដើមបណ្ដឹងឧទ្ធរណ៍ស្វះស្វែងដើម្បីប្ដឹងតវ៉ានេះ បង្កើតបានជាកាលៈទេសៈពិសេស ដែលមានចែងក្នុងសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ និងអនុញ្ញាតឲ្យមានការបន្ថែមចំនួនទំព័របាន។ ជាពិសេស អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្ដីនឹងត្រូវឆ្លើយតប ចំពោះខ្លឹមសារនៃបញ្ហាយុត្តាធិការដែលចោទជាបញ្ហានេះជាមុនសិន មុននឹងលើកឡើងពីទឡ្ហីករណ៍របស់ខ្លួនស្ដីពីអង្គសេចក្ដី។

១១. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា វាជាផលប្រយោជន៍របស់ជនត្រូវចោទក្នុងការទទួលបាននូវដំណោះស្រាយលើបញ្ហាយុត្តាធិការទាំងនេះឲ្យបានពេញលេញ និងទូលំទូលាយតាមដែលអាចធ្វើទៅបាន ហើយសហព្រះរាជអាជ្ញាក៏នឹងត្រូវបានផ្ដល់ឱកាសដូចគ្នានេះដែរ ប្រសិនខ្លួនស្វែងរកការសុំបន្ថែមចំនួនទំព័រ ដើម្បីជាការឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ដែលបានលើកឡើងនេះ។ ការផ្ដល់ឱកាសបែបនេះនឹងជួយឲ្យអង្គជំនុំជម្រះទទួលបានឯកសារគ្រប់គ្រាន់ ដើម្បីពិចារណាឲ្យបានសមស្រប ទៅលើបញ្ហាទាំងអស់ដែលបានលើកឡើងនោះ។

## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច ÷

**អនុញ្ញាត** តាមសំណើសុំបន្ថែមចំនួនទំព័រសម្រាប់បណ្ដឹងឧទ្ធរណ៍នេះ ដែលមានចំនួនសរុប ១៨០ ទំព័រជាភាសាអង់គ្លេស។

ភ្នំពេញ ថ្ងៃទី១ ខែតុលា ឆ្នាំ២០១០

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**